ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# កិច្ចសន្យាអនុវត្តការងារ

លេខ៖ ១១/១១ FWUC_SK-ISC

គាំទ្រលើកិច្ចដំណើរការគ្រប់គ្រងហិរញ្ញវត្ថុ

សហគមន៍កសិករប្រើប្រាស់ទឹកប្រព័ន្ធធារាសាស្ត្រ

ស្តៅកោង ខេត្តព្រៃវែង

*រយៈពេលបីខែ ចាប់ពីចុងខែមេសា ឆ្នាំ២០១១ដល់ ខែកក្កដា ឆ្នាំ២០១១*

*សំរាប់រដូវស្រោចស្រពទី១១*

**រវាង**

**គណៈកម្មាធិការសហគមន៍កសិករប្រើប្រាស់ទឹកស្តៅកោង**

**និង**

**មជ្ឈមណ្ឌលសេវាកម្មធារាសាស្ត្រ**

**ខេត្តកំពង់ធំ**

ខែមេសា ឆ្នាំ ២០១១

# កិច្ចសន្យាអនុវត្តការងារ

*កំឡុងពេល ខែមេសា ឆ្នាំ២០១១ដល់ ខែកក្កដា ឆ្នាំ២០១១*
*គាំទ្រលើកិច្ចដំណើរការគ្រប់គ្រងហិរញ្ញវត្ថុសហគមន៍កសិករប្រើប្រាស់ទឹក*
*ប្រព័ន្ធធារាសាស្ត្រស្តៅកោង ខេត្តព្រៃវែង*
លេខ៖ ១១/១១ FWUC_SK-ISC

*កិច្ចសន្យានេះរៀបចំឡើងរវាង សហគមន៍កសិករប្រើប្រាស់ទឹកប្រព័ន្ធធារាសាស្ត្រស្តៅកោង ជាភាគីម្ចាស់គម្រោង ដែលតំណាងដោយ លោក **ស៊ឹម ស្រួយ** ជាប្រធានគណៈកម្មាធិការសហគមន៍ប្រើប្រាស់ទឹកប្រព័ន្ធធារាសាស្ត្រស្តៅកោង និង មជ្ឈមណ្ឌលសេវាកម្មធារាសាស្ត្រ ជាភាគីអនុវត្តគម្រោង ដែលតំណាងដោយ លោក សេង សុភ័គ ជាអ្នកសម្របសម្រួលមជ្ឈមណ្ឌលសេវាកម្ម ធារាសាស្ត្រ។*

## ប្រការ ១ គោលបំណង

មជ្ឈមណ្ឌលសេវាម្មធារាសាស្ត្រ នឹងផ្តល់សេវាកម្មជូនសហគមន៍កសិករប្រើប្រាស់ទឹកស្តៅកោង កំឡុងពេល ខែមេសា ឆ្នាំ២០១១ដល់ ខែកក្កដា ឆ្នាំ២០១១ ៖

**១.** ត្រួតពិនិត្យលើដំណើរការគ្រប់គ្រងហិរញ្ញវត្ថុក្នុងសហគមន៍
- ការគ្រប់គ្រងចំណូលចំណាយក្នុងសហគមន៍
- ការគ្រប់គ្រងបញ្ជីស្នាម និងរៀបចំទុកដាក់ឯកសារ
- ការកត់ត្រាចំណូលចំណាយក្នុងប្រព័ន្ធគណនេយ្យ
- ត្រួតពិនិត្យរបាយការណ៍ចំណូលចំណាយ
- របាយការណ៍ហិរញ្ញវត្ថុប្រចាំរដូវ
- រៀបចំគម្រោងថវិកាសំរាប់រដូវបន្ទាប់

**២.** រៀបចំបង្កើតនិតិវិធីគ្រប់គ្រងហិរញ្ញវត្ថុ
- ប្រមូលព័ត៌មានទាក់ទងនឹងដំណើរការគ្រប់គ្រងហិរញ្ញវត្ថុ
- ពង្រាងនិតិវិធីគ្រប់គ្រងហិរញ្ញវត្ថុជាមួយគណៈកម្មាធិការសហគមន៍
- ឆ្លងពង្រាងនិតិវិធីគ្រប់គ្រងហិរញ្ញវត្ថុជាមួយគណៈកម្មាធិការសហគមន៍ និងកែសម្រួល
- ឆ្លងពង្រាងនិតិវិធីគ្រប់គ្រងហិរញ្ញវត្ថុជាមួយសមាជិកសហគមន៍ និងកែសម្រួល
- ឆ្លង និងអនុម័តនិតិវិធីគ្រប់គ្រងហិរញ្ញវត្ថុជាមួយគណៈកម្មាធិការ និងសមាជិកដើម្បីដាក់អោយប្រើប្រាស់ក្នុងសហគមន៍

## ប្រការ ២ គម្រោងចំណាយលើការអនុវត្តន៍សកម្មភាពការងារក្នុងកិច្ចសន្យា

ការចំណាយលើការអនុវត្តន៍សកម្មភាពការងារខាងលើនេះ អស់ទឹកប្រាក់សរុបចំនួន ១,000,000រៀល (មួយលានរៀលគត់)។

រាល់ការចំណាយផ្សេងៗលើការអនុវត្តន៍សកម្មភាពការងារខាងលើនេះ សហគមន៍កសិករប្រើប្រាស់ទឹកប្រព័ន្ធធារាសាស្ត្រស្ពៅកោង ជាអ្នកទទួលខុសត្រូវ។

**ប្រការ ៣ ការបង់ប្រាក់ថ្លៃអនុវត្តសកម្មភាពការងារ**

ការបង់ប្រាក់ នឹងត្រូវធ្វើឡើងដោយសាច់ប្រាក់សុទ្ធ ឬតាមរយៈការផ្ទេរប្រាក់ចូលទៅក្នុងគណនីរបស់មជ្ឈមណ្ឌលសេវាកម្មធារាសាស្ត្រផ្ទាល់ បន្ទាប់ពីការវាយតំលៃលើការអនុវត្តន៍សកម្មភាពការងារ ដោយគណៈកម្មាធិការសហគមន៍កសិករប្រើប្រាស់ទឹកប្រព័ន្ធធារាសាស្ត្រស្ពៅកោង នៅចុងបញ្ចប់រដូវស្រោចស្រព។

**ប្រការ ៤ ឯកសារផ្សេងៗ និងរបាយការណ៍បញ្ចប់ការអនុវត្តន៍សកម្មភាពការងារ**

ក្រោយពេលបញ្ចប់កិច្ចសន្យា រយៈពេលពីរសប្តាហ៍ មជ្ឈមណ្ឌលសេវាកម្មធារាសាស្ត្រ នឹងផ្តល់របាយការណ៍បញ្ចប់ការអនុវត្តន៍សកម្មភាពការងារតាមកិច្ចសន្យាជូនគណៈកម្មាធិការសហគមន៍កសិករ ប្រើប្រាស់ ទឹកប្រព័ន្ធធារាសាស្ត្រស្ពៅកោង។

**ប្រការ ៥ ការវាយតំលៃលើការអនុវត្តន៍គម្រោង**

ការវាយតំលៃលើការអនុវត្តន៍សកម្មភាពការងារ ដោយគណៈកម្មាធិការក្រុមកសិករប្រើប្រាស់ទឹកប្រព័ន្ធធារាសាស្ត្រស្ពៅកោង ត្រូវធ្វើនៅចុងបញ្ចប់រដូវស្រោចស្រព។ ការវាយតំលៃនេះ ផ្តោតសំខាន់ទៅលើពីរចំណុចៈ ១. ការសំរេចនូវគោលបំណង ដូចមានចែងក្នុងប្រការ១ និង ២. ធ្វើការឆ្លុះបញ្ចាំងលើនិតិវិធីនៃកិច្ចសហការក្នុងការអនុវត្តន៍ការងារកន្លងមក ដើម្បីស្វែងរកចំណុចល្អ និងចំណុចត្រូវកែលំអសំរាប់អនុវត្តទៅថ្ងៃអនាគត។

**ប្រការ ៦ ការដោះស្រាយទំនាស់**

ករណីមានទំនាស់កើតឡើងពាក់ព័ន្ធនិងកិច្ចសន្យានេះ ភាគីទាំងពីរ នឹងជួបពិភាក្សាគ្នាដើម្បីរកដំណោះស្រាយសមស្របមួយដែលអាចទទួលបានការឯកភាពពីភាគីទាំងពីរ។ ករណីមិនអាចពិភាក្សា រវាងភាគីទាំងពីរទំនាស់នេះ នឹងបញ្ជូនទៅដោះស្រាយនៅតុលាកម្ពុជា។

**ប្រការ ៧ សុពលភាពនៃកិច្ចសន្យា**

កិច្ចសន្យានេះ នឹងមានសុពលភាពចាប់ពីថ្ងៃចុះហត្ថលេខា រវាងគណៈកម្មាធិការសហគមន៍កសិករប្រើប្រាស់ស្ពៅកោង និងតំណាងមជ្ឈមណ្ឌលសេវាកម្មធារាសាស្ត្រ។

**ប្រការ ៨ ការធ្វើវិសោធនកម្មនៃកិច្ចសន្យា**

កិច្ចសន្យានេះ អាចនឹងត្រូវធ្វើការកែប្រែ ករណីមានការឯកភាពទាំងពីរភាគី រវាងគណៈកម្មាធិការសហគមន៍ កសិករប្រើប្រាស់ស្ពៅកោង និងតំណាងមជ្ឈមណ្ឌលសេវាកម្មធារាសាស្ត្រ។

ធ្វើនៅ ស្ពៅកោង ថ្ងៃទី ២៧ ខែមេសា ឆ្នាំ ២០១១

| | |
|---|---|
| *មជ្ឈមណ្ឌលសេវាកម្មធារាសាស្ត្រ* | *គណៈកម្មាធិការសហគមន៍កសិករប្រើប្រាស់ទឹក* |
| *អ្នកសម្របសម្រួល* | *ប្រព័ន្ធធារាសាស្ត្រស្ពៅកោង* |
| | *ប្រធាន* |
| **សេង សុភ័គ** | **ស៊ឹម ស្រួយ** |